**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **ក្រសួងសុខាភិបាល**

**លេខ**......៧៩១......**ក.ប**/ប្រ.ក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាង បេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ និង នីតិវិធីនៃការចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ៖

- សេវាសុខាភិបាល សំដៅដល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព។
- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សំដៅដល់សេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រ និងសេវាជំនួយវេជ្ជសាស្ត្រ។
- សេវាវេជ្ជសាស្ត្រ សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- សេវាអមវេជ្ជសាស្ត្រ សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- សេវាជំនួយវេជ្ជសាស្ត្រ សំដៅដល់ការព្យាបាលដោយស្ពឹ និងដោយចលនា។
- មូលដ្ឋានសុខាភិបាល សំដៅដល់អង្គភាពព្យាបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

- កិច្ចព្រមព្រៀង សំដៅដល់នីតិវិធីនិងបែបបទនៃការផ្តល់សេវាសុខាភិបាលដោយមូលដ្ឋានសុខាភិបាលនិងការប្រើប្រាស់សេវាសុខាភិបាលរបស់សមាជិកបេឡា-ជាតិរបបសន្តិសុខសង្គម (ប.ស.ស) ។

**ប្រការ ៣.-**

**៣.១** មូលដ្ឋានសុខាភិបាលសាធារណៈត្រូវមានកាតព្វកិច្ចចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដោយអនុវត្តតាមទម្រង់កិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន្ធ១ សម្រាប់មណ្ឌលសុខភាព ឧបសម្ព័ន្ធ២ សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ និងឧបសម្ព័ន្ធ៣ សម្រាប់មន្ទីរពេទ្យជាតិ។

**៣.២** មូលដ្ឋានសុខាភិបាលឯកជន អាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស បានលុះត្រាតែមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពសេវាពី ប.ស.ស។

**៣.៣** ប.ស.ស អាចចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ដោយផ្អែកលើសេចក្តីត្រូវការចាំបាច់ ទីតាំងភូមិសាស្ត្រ និងស្ថានភាពមូលដ្ឋានសុខាភិបាលព្រមទាំងមានធនធានហេដ្ឋារចនាសម្ព័ន្ធសមស្រប ឬគ្រប់គ្រាន់ សម្រាប់ការផ្តល់សេវាសុខាភិបាលឲ្យមានគុណភាព ក្នុងនោះរួមមានៈ

- អគារសមរម្យ និងបរិស្ថានអនាម័យល្អ
- ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយចាំបាច់នានាសម្រាប់គាំទ្រការធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលនិងថែទាំតាមវិធាន បទបញ្ជា និងអាជ្ញាប័ណ្ណផ្សេងៗរបស់ក្រសួងសុខាភិបាល។ បុគ្គលិកសុខាភិបាលមានសមត្ថ-ភាពបច្ចេកទេស និងក្រមសីលធម៌ និងមានចំនួនសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល។

**ប្រការ ៤.-**

**៤.១** ការទូទាត់ថ្លៃសេវា ជូនមូលដ្ឋានសុខាភិបាល អាចធ្វើទៅបានលុះត្រាតែមានការកំណត់ពីលទ្ធភាពផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ កម្រិតនៃការទូទាត់ថ្លៃតាមប្រភេទករណី និងកម្រិតនៃការទូទាត់ថ្លៃតាមប្រភេទសេវា ដោយ ប.ស.ស។ ទោះជាយ៉ាងណាក៏ដោយ ការកំណត់ពីកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលនេះ មិនត្រូវទាបជាងកម្រិតកំណត់ដោយក្រសួងសុខាភិបាលឡើយ។

**៤.២** ការទូទាត់ថ្លៃសេវា ជូនមូលដ្ឋានសុខាភិបាល ត្រូវអនុវត្តតាមយន្តការទូទាត់ថ្លៃសេវាដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព។

៤.៣ ប.ស.ស ត្រូវទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង តាមរយៈប្រព័ន្ធធនាគារ។ ការទូទាត់នេះត្រូវធ្វើឡើងទៅតាមកាលវិភាគ បែបបទ និងនីតិវិធី ដូចមានចែងក្នុងឧបសម្ព័ន្ធនីមួយៗនៃប្រកាសនេះ។

៤.៤ ប.ស.ស អាចបដិសេធការទូទាត់ថ្លៃសេវាទាំងស្រុង ឬមួយផ្នែកនៃថ្លៃសេវាដែលស្នើដោយមូលដ្ឋានសុខាភិបាល នៅក្នុងករណីដូចខាងក្រោម៖

- សេវាសុខាភិបាលដែលផ្តល់ឲ្យ លើសពីតម្រូវការចាំបាច់ នៃបញ្ហាសុខភាព ឬលក្ខខណ្ឌជំងឺ។
- អន្តរាគមន៍ ឬ បែបបទនៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់ការព្យាបាល និងថែទាំមិនស្របតាមពិធីសារ នៃការព្យាបាល ឬ គោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងសុខាភិបាល។
- ប្រើប្រាស់ឱសថមានគុណភាពអន់ ឬ គ្មានប្រភពច្បាស់លាស់ ឬគ្មានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងការចេញវេជ្ជបញ្ជាមិនត្រឹមត្រូវ។
- ក្លែងបន្លំឯកសារ ឬ ផ្តល់ព័ត៌មានមិនពិត ដែលជាយន្តការសម្រាប់ការទូទាត់ថ្លៃសេវា។ និង
- ការទទួលយកនូវការអនុវត្តតាមបទដ្ឋាន និងការព្យាបាលដែលមានគម្លាតខុសគ្នាទាំងស្រុង។

**ប្រការ ៥.-**

៥.១ ប.ស.ស ត្រូវត្រួតពិនិត្យតាមដានគុណភាពសេវាសុខាភិបាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលបានចុះកិច្ចព្រមព្រៀង និង និន្នាការនៃការប្រើប្រាស់សេវាសុខាភិបាលរបស់សមាជិក ប.ស.ស ដោយអនុវត្តយន្តការត្រួតពិនិត្យតាមដានជាកាលិក ព្រមទាំងសហប្រតិបត្តិការផ្តល់ព័ត៌មានទៅវិញទៅមក ដើម្បីលើកកម្ពស់គុណភាពសេវាជាប្រចាំ និងតម្រង់ទិសការប្រើប្រាស់សេវារបស់សមាជិក ប.ស.ស ឲ្យមានប្រសិទ្ធភាព។

៥.២ ការត្រួតពិនិត្យតាមដានគុណភាពសេវាសុខាភិបាល ត្រូវផ្តោតជាចំបងលើវេទនាសម្ព័ន្ធគុណភាពសេវា កម្រិតផ្តល់សេវា បែបបទ នៃការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលនិងថែទាំ ព្រមទាំងកម្រិតនៃការពេញចិត្តចំពោះគុណភាពសេវារបស់សមាជិក ប.ស.ស ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃគុណភាពសេវា ដែលកំណត់ដោយក្រសួងសុខាភិបាល។

**ប្រការ ៦.-**

ដើម្បីធានាបាននូវគុណភាពសេវាជូនសមាជិក ប.ស.ស ត្រូវកំណត់ពីវិធីសាស្ត្រ និងនីតិវិធី ក្នុងការវាស់វែងពីប្រសិទ្ធភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង។

**ប្រការ ៧.-**

ប.ស.ស និងមូលដ្ឋានសុខាភិបាល ត្រូវដោះស្រាយវិវាទដែលអាចកើតមានជាយថាហេតុ ដោយសន្តិវិធី ឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី ឬតាមរយៈក្រសួងអាណាព្យាបាល បើសិនចាំបាច់។

**ប្រការ ៨.-**

បេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង អាចធ្វើការពិនិត្យ និងសើរើកិច្ចព្រមព្រៀងជាថ្មី ដោយផ្អែកលើគុណភាពសេវា កម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល និងសេចក្តីត្រូវការចាំបាច់របស់សមាជិក។

**ប្រការ ៩.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

ម៉ម ប៊ុនហេង

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

អ៊ិត សំហេង

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល

# រវាង

# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

# និង

# មណ្ឌលសុខភាព..................

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើង រវាង:

**បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

មណ្ឌលសុខភាព................................................មានទីតាំងស្ថិតនៅអាគារលេខ............. ភូមិ..........................ឃុំ/សង្កាត់............................ស្រុក/ខណ្ឌ/ក្រុង......................រាជធានី/ខេត្ត ..................................... ដែលតទៅនេះហៅថា **ភាគី "ខ"**។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី "ក"** និង **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោម៖

## ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅៈ

- *សមាជិក ប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅ សហគ្រាស គ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាមីជនមានបញ្ហាសុខភាព ឬគ្រោះថ្នាក់។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ "**ប័ណ្ណសមាជិក**" និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិក ត្រូវមាន "**ការទទួលស្គាល់ពី ប.ស.ស**"។
- *សហគ្រាស គ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាពក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព ដែលផ្ដល់ដោយមូលដ្ឋានសុខាភិបាល ។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្ដល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្ដល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យនិងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

## ប្រការ ២_. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"

ក. ដើម្បីផ្ដល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថាៈ

ក.១ មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមណ្ឌលសុខភាព ២៤/២៤ម៉ោង និង ០៧(ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។ រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាល មិនត្រូវយឺតយូរ និងគ្មានហេតុផល បន្ទាប់ពីអ្នកជំងឺ ឬជនរងគ្រោះចូលដល់មណ្ឌលសុខភាព។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ ដែលបានកំណត់នៅក្នុងបញ្ជីឱសថសារវ័ន្តរបស់ក្រសួងសុខាភិបាល។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុងគោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែលលើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៤ នៃឧបសម្ព័ន្ធនេះ។

ក.៦ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះ និងព្យាបាលជម្ងឺទូទៅ និងជម្ងឺឯកទេស
- ពិគ្រោះ និងព្យាបាលជាមួយនឹងការវះកាត់តូច
- ពិគ្រោះ និងការពិនិត្យផ្ទៃពោះមុនសម្រាល(រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការថែទាំព្យាបាល ក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមណ្ឌលសុខភាព
- សម្រាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣ Active Management of the Third Stage of Labor (AMTSL) ការដេរស្នាមកាត់ ឬដាច់ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និងតាមដានក្រោយ សម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមណ្ឌលសុខភាព។
- សេវារំលូត និងសំអាតក្រោយរំលូត
- សេវាមន្ទីរពិសោធន៍ និងសេវាអមគ្លីនិកផ្សេងៗទៀត

- សេវាបង្ការសុខភាពៈ ការពន្យារកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កងក្នុងស្បូន និងដៃ...)
- សេវាពិនិត្យជម្ងឺក្រៅ រួមបញ្ចូលទាំងការពិគ្រោះជំងឺ ការផ្តល់ឱសថសារវន្ត ការផ្តល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ ។
- សេវាសម្រាកពេទ្យ រួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថសារវន្ត សេវាអមគ្លីនិកផ្សេងទៀត ឧបករណ៍ និងការថែទាំទាំងអស់។

ក.៧ ផ្តល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១.ការព្យាបាលមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣. ការព្យាបាល និងវះកាត់ប្តូរភេទ
៤. ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ
៥. សេវាបង្កកំណើតដោយសិប្បនិម្មិត
៦. ការព្យាបាលដោយខ្លួនឯង
៧. ការព្យាបាល ឬវះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត
១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
១៣. ការលាងឈាម
១៤. ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ខែឧសភា ឆ្នាំ ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ និង

ក.៨ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬព្យាបាលបាន ឬមិនអាចផ្តល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេង

ទៀតដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាង ដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ខ. ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា **ភាគី "ខ"** ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬ គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅ៖

ខ.១ ពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវា របស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬស្នាមម្រាមដៃ(Finger Print) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បី៖

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង
- ពិនិត្យឯកសារអ្នកជំងឺ ឬ ជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀត ទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលាបន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងក្នុងចំណុច ៣.៤ នៃឧបសម្ព័ន្ធនេះ។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត របស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី "ក"** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។ និង

ខ.៧ ជានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាព បន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី "ខ"** វិញ ល្ហឹកណាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី "ខ"** មិនលើសពី ៤៨ម៉ោង នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

**គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោមៈ**

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ទិន្នន័យប្រើប្រាស់សេវា ដោយមានតម្លៃតាមប្រភេទករណី(Case-based) និងតម្លៃតាមប្រភេទសេវា(Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជ-សាស្ត្រនិងលទ្ធផល និង វេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាពរបស់សមាជិក ប.ស.ស។ និង

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

## ប្រការ ៣.- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ក"

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវ ដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី "ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និង

អនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"** ដូចខាងក្រោម៖

| *សូចនាករណ៍វាយតម្លៃគុណភាពសេវា* | | | |
|---|---|---|---|
| **សូចនាករណ៍(Indicator)** | **ទិសដៅ** | **មធ្យោបាយផ្ទៀងផ្ទាត់** | **ពេលវេលា** |
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០ នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| របាយការណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពីបុគ្គលិក ពេទ្យយ៉ាងតិច ២ ដងក្នុង ១ថ្ងៃ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"** | |
|---|---|
| **ពិន្ទុ** | **អត្រានៃការបង់ថ្លៃសេវា** |
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬ តិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

៣.៥ ផ្តល់ឲ្យ **ភាគី "ខ"** នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកានៅ ប.ស.ស ។

៣.៦ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានត្រលប់ទៅឲ្យ **ភាគី "ខ"** ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី "ខ"** ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

**ប្រការ ៤_. យន្តការដោះស្រាយវិវាទ**

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

**ប្រការ ៥_. ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវា និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណ-ភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ) ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦.. ប្រសិទ្ធភាពនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី...........ខែ...............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**

បានឃើញ និងបញ្ជូនមក
លោកប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត........
ដើម្បីពិនិត្យ និងសម្រេច។
ធ្វើនៅ...........ថ្ងៃទី..........ខែ.........ឆ្នាំ ២០១៦
ប្រធានការិយាល័យស្រុកប្រតិបត្តិ.............

បានឃើញ និងឯកភាព
ធ្វើនៅ..................ថ្ងៃទី...........ខែ...........ឆ្នាំ២០១៦
**ប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត.........**

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល
# រវាង
# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)
# និង
# មន្ទីរពេទ្យបង្អែក...............

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើងរវាងៈ

**បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

មន្ទីរពេទ្យបង្អែក...........................................មានទីតាំងស្ថិតនៅអាគារលេខ.................. ភូមិ.....................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ/ក្រុង.............................រាជធានី/ខេត្ត ............................. ដែលតទៅនេះហៅថា **ភាគី "ខ"** ។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី "ក"** និង **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោមៈ

## ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅៈ

- *សមាជិកប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅសហគ្រាស គ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាម៉ីជនមានបញ្ហាសុខភាពឬគ្រោះថ្នាក់ ។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ"ប័ណ្ណសមាជិក"និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិកត្រូវមាន"**ការទទួលស្គាល់ពី ប.ស.ស**" ។
- *សហគ្រាស គ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនទាំងឡាយ ដែលបានចុះបញ្ជិកាក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងសេវាស្តារនីតិសម្បទាដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្តល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា ។
- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល ។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។

- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

**ប្រការ ២_. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"**

ក. ដើម្បីផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថា៖

ក.១ មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមន្ទីរពេទ្យបង្អែក ២៤/២៤ម៉ោង និង ០៧(ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាលមិនត្រូវយឺតយូរ និងគ្មានហេតុផលបន្ទាប់ពីអ្នកជំងឺ ឬ ជនរងគ្រោះចូលដល់មន្ទីរពេទ្យបង្អែក។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ ដែលបានកំណត់នៅក្នុងគោលនយោបាយសុខាភិបាលសារធារណៈ។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុង គោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ ត្រូវធានាផ្តល់ឱសថ និងសេវាអមវេជ្ជសាស្ត្រ ជូនសមាជិក ប.ស.ស ឲ្យបានគ្រប់គ្រាន់ទោះជាក្នុងស្ថានភាពណាក៏ដោយ។

ក.៦ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែលលើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៣ នៃឧបសម្ព័ន្ធនេះ។

ក.៧ សមាជិកប.ស.ស អាចទទួលបាននូវអាហារក្នុងរយៈពេលសម្រាកពេទ្យ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក.៨ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះ និងព្យាបាលជំងឺទូទៅ និងជំងឺឯកទេស
- ពិគ្រោះ និងព្យាបាលជំងឺរោគស្ត្រី
- ពិគ្រោះ និងព្យាបាលជាមួយ និងការវះកាត់
- ពិគ្រោះ និងព្យាបាលជំងឺទូទៅផ្នែកកុមារ
- ពិគ្រោះ និងព្យាបាលមាត់ធ្មេញ
- ពិគ្រោះពិនិត្យតាមដានផ្ទៃពោះមុនសម្រាល ( រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការព្យាបាល និងថែទាំវេជ្ជសាស្ត្រក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យ
- សម្រាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣(AMTSL) ការដេរស្នាមកាត់ ឬដាច់ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និងតាមដានក្រោយសម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមន្ទីរពេទ្យ។
- រំលូត និងសំអាតក្រោយរលូត
- សេវាអមគ្លីនិកផ្សេងៗទៀត
- ការវះកាត់
- សង្គ្រោះបន្ទាន់
- សម្រាកពេទ្យផ្នែកសល្យសាស្ត្រ
- បង្ការសុខភាពៈ ការពន្យាកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កងក្នុងស្បូន និងដៃ)
- សេវាពិនិត្យជំងឺក្រៅ រួមបញ្ចូលទាំង ការពិគ្រោះជំងឺ ការផ្តល់ឱសថ ការផ្តល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ។
- សេវាសម្រាកពេទ្យ រួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថ សេវាអមគ្លីនិកផ្សេងៗទៀត ឧបករណ៍ និងការថែទាំទាំងអស់។

- បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងបញ្ជូនសព។

ក.៩ ផ្តល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១-ការព្យាបាលមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២-ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

៣-ការព្យាបាល និងវះកាត់ប្តូរភេទ

៤- ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ

៥- សេវាបង្កកំណើតដោយសិប្បនិម្មិត

៦- ការព្យាបាលដោយខ្លួនឯង

៧- ការព្យាបាល ឬវះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន

១០- ការព្យាបាលអសមត្ថភាពផ្តល់កំណើត

១១- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង

១៣- ការលាងឈាម

១៤- ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តន៍ការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ក.១០ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬព្យាបាលបាន ឬមិនអាចផ្តល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេងទៀតដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាងដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ក.១១ ចំពោះការផ្តល់ឈាម ប.ស.ស អនុវត្តតាមគោលនយោបាយសុខាភិបាលសាធារណៈ។

ខ. ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា **ភាគី "ខ"** ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅ៖

ខ.១ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ខ"** ត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវារបស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬស្នាមម្រាមដៃ(Finger print) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បី៖

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង
- ពិនិត្យឯកសារអ្នកជំងឺ ឬជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពី ការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលា បន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការ

វាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់ ០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងនៅក្នុងតារាងទី១។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប /ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី "ក"** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។

ខ.៧ ធានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាព បន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី "ខ"** វិញ ល្ពឹកណាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី "ខ"** មិនលើសពី ៤៨ ម៉ោងនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

ខ.៨ ទទួលយកការដាក់ភ្នាក់ងារ និងមានបន្ទប់ធ្វើការសម្រាប់ភ្នាក់ងារ ប.ស.ស នៅក្នុងមន្ទីរពេទ្យបង្អែកជាការចាំបាច់។

**គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖**

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ ទិន្នន័យប្រើប្រាស់សេវាដោយ មានតម្លៃតាមប្រភេទករណី (Case-based) និងតម្លៃតាមប្រភេទសេវា (Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជសាស្ត្រ និងលទ្ធផល និងវេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាពមន្ទីរពេទ្យបង្អែករបស់សមាជិកប.ស.ស។

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

## ប្រការ ៣ _. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ក"

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគីភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី"ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវ ដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី"ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី"ខ"** ដូចខាងក្រោម៖

តារាងទី១. សូចនាករណ៍វាយតម្លៃគុណភាពសេវា

| សូចនាករណ៍(Indicator) | ទិសដៅ | មធ្យោបាយផ្ទៀងផ្ទាត់ | ពេលវេលា |
|---|---|---|---|
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| របាយការណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប. ស.ស. | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពីបុគ្គលិក | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ | ០៦ខែម្តង |

| | | | |
|---|---|---|---|
| ពេទ្យយ៉ាងតិច ២ ដងក្នុង១ថ្ងៃ | | ប.ស.ស | |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| តារាងទី២. ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"** | |
|---|---|
| ពិន្ទុ | អត្រានៃការបង់ថ្លៃសេវា |
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬតិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

ការទូទាត់ និងការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី៖

- **ភាគី "ក"** នឹងទូទាត់ ១០០% ទៅតាមប្រភេទករណី ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀង រហូតដល់មានការវាយតម្លៃសូចនាករណ៍គុណភាពសេវា។
- ការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី ត្រូវអនុលោមទៅតាមពិន្ទុវាយតម្លៃសូចនា-ករណ៍គុណភាពសេវាដូចមានចែងក្នុងតារាងទី២ ដែលធ្វើឡើងដោយ ប.ស.ស។

៣.៥ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ក"** ត្រូវផ្តល់នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ដល់ **ភាគី "ខ"** ។

៣.៦ ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានគ្រលប់ទៅឲ្យ **ភាគី "ខ"** ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី "ខ"** ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

**ប្រការ ៤ _. យន្តការដោះស្រាយវិវាទ**

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

**ប្រការ ៥ _. ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវានិងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ)ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦ _. ប្រសិទ្ធភាព នៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី............ខែ...............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**

បានឃើញ និងបញ្ជូនមក
លោកប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត........
ដើម្បីពិនិត្យ និងសម្រេច។
ធ្វើនៅ...........ថ្ងៃទី.....ខែ.........ឆ្នាំ ២០១៦
**ប្រធានការិយាល័យស្រុកប្រតិបត្តិ.............**

បានឃើញ និងឯកភាព
ធ្វើនៅ...........ថ្ងៃទី.....ខែ.........ឆ្នាំ ២០១៦

**ប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត.........**

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល

# រវាង

# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

# និង

# មន្ទីរពេទ្យ................

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើងរវាង:

**បេឡាជាតិរបបសន្តិសុខសង្គម** (**ប.ស.ស**) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី** "**ក**" ។

និង

មន្ទីរពេទ្យ.......................................................មានទីតាំងស្ថិតនៅអាគារលេខ.................. ភូមិ.....................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ/ក្រុង.............................រាជធានី/ខេត្ត.............................. ដែលតទៅនេះហៅថា **ភាគី** "**ខ**" ។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី** "**ក**" និង **ភាគី** "**ខ**" ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោមៈ

## ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅ៖

- *សមាជិក ប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅសហគ្រាសគ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាមីជនមានបញ្ហាសុខភាពឬគ្រោះថ្នាក់ ។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ"ប័ណ្ណសមាជិក"និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិកត្រូវមាន "**ការទទួលស្គាល់ពី ប.ស.ស**" ។
- *សហគ្រាសគ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនទាំងឡាយ ដែលបានចុះបញ្ជិកាក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងសេវាស្តារនីតិសម្បទាដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្តល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជ-សាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា ។
- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល ។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

**ប្រការ ២. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"**

ក. ដើម្បីផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថា៖

ក.១. មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមន្ទីរពេទ្យ ២៤/២៤ម៉ោង និង០៧ (ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។ រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាលមិនត្រូវយឺតយូរ និងគ្មានហេតុផល បន្ទាប់ពីអ្នកជំងឺ ឬជនរងគ្រោះចូលដល់មន្ទីរពេទ្យ។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ ដែលបានកំណត់នៅក្នុងគោលនយោបាយសុខាភិបាលសារធារណៈ។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុងគោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ ត្រូវធានាផ្តល់ឱសថ និងសេវាអមវេជ្ជសាស្ត្រ ជូនសមាជិក ប.ស.ស ឲ្យបានគ្រប់គ្រាន់ទោះជាក្នុងស្ថានភាពណាក៏ដោយ។

ក.៦ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែលលើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៣ នៃឧបសម្ព័ន្ធនេះ។

ក.៧ សមាជិកប.ស.ស អាចទទួលបាននូវអាហារក្នុងរយៈពេលសម្រាកពេទ្យ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក.៨ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះនិងព្យាបាលជំងឺទូទៅ និងជំងឺឯកទេស
- ពិគ្រោះ និងព្យាបាលជំងឺរោគស្ត្រី
- ពិគ្រោះនិងព្យាបាលជាមួយ និងការវះកាត់
- ពិគ្រោះ និងព្យាបាលជំងឺទូទៅផ្នែកកុមារ
- ពិគ្រោះនិងព្យាបាលមាត់ធ្មេញ

- ពិគ្រោះពិនិត្យតាមដានផ្ទៃពោះមុនសម្រាល (រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យ
- សំរាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣(AMTSL) ការដេរស្នាមកាត់ ឬដាច់ ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និងតាមដានក្រោយសម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមន្ទីរពេទ្យ។
- រំលូត និងសំអាតក្រោយរលូត
- មន្ទីរពិសោធន៍ និងសេវាអមគ្លីនីកផ្សេងៗទៀត
- ការវះកាត់
- សង្គ្រោះបន្ទាន់
- សម្រាកពេទ្យផ្នែកសល្យសាស្ត្រ
- បង្ការសុខភាពរួមមាន ការពន្យាកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កង ក្នុងស្បូន និងដៃ)
- សេវាពិនិត្យជំងឺក្រៅ រួមបញ្ចូលទាំង ការពិគ្រោះជំងឺ ការផ្តល់ឱសថ ការផ្តល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ។
- សេវាសម្រាកពេទ្យរួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថ សេវាអមគ្លីនិកផ្សេងៗទៀត ឧបករណ៍ និងការថែទាំទាំង-អស់។
- បញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងបញ្ជូនសព។

ក.៩ ផ្តល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១. ការព្យាបាលមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣. ការព្យាបាល និងវះកាត់ប្តូរភេទ
៤. ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ
៥. សេវាបង្កកំណើតដោយសិប្បនិម្មិត
៦. ការព្យាបាលដោយខ្លួនឯង
៧. ការព្យាបាល ឬវះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត
១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
១៣. ការលាងឈាម
១៤. ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ក.១០ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬព្យាបាលបាន ឬមិនអាចផ្តល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេងទៀត ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាង ដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ក.១១ ចំពោះការផ្តល់ឈាម ប.ស.ស អនុវត្តន៍តាមគោលនយោបាយសុខាភិបាលសាធារណៈ។

**ខ. ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅៈ**

ខ.១ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ខ"** ត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវារបស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬ ស្នាមម្រាមដៃ(Fingerprint) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បីៈ

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង

- ពិនិត្យឯកសារអ្នកជំងឺឬជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពី ការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលាបន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់ ០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងនៅក្នុងតារាងទី១។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី "ក"** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។

ខ.៧ ធានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាពបន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី "ខ"** វិញ លុះត្រាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី "ខ"** មិនលើសពី ៤៨ម៉ោង នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

ខ.៨ ទទួលយកការដាក់ភ្នាក់ងារ និងមានបន្ទប់ធ្វើការសម្រាប់ភ្នាក់ងារ ប.ស.ស នៅក្នុងមន្ទីរពេទ្យបង្អែកជាការចាំបាច់។

**គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖**

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ ទិន្នន័យប្រើប្រាស់សេវាដោយ មានតម្លៃតាមប្រភេទករណី(Case-based) និងតម្លៃតាមប្រភេទសេវា(Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជ-

សាស្ត្រនិងលទ្ធផល និងវេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែករបស់សមាជិក ប.ស.ស។ និង

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

## ប្រការ ៣. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី"ក"

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី"ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវ ដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី"ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី"ខ"** ដូចខាងក្រោមៈ

| តារាងទី១. សូចនាករណ៍វាយតម្លៃគុណភាពសេវា | | | |
|---|---|---|---|
| សូចនាករណ៍(Indicator) | ទិសដៅ | មធ្យោបាយផ្ទៀងផ្ទាត់ | ពេលវេលា |
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| | | | |
|---|---|---|---|
| របាយការណ៍អំពីឥរិយាបថល្អ របស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពី បុគ្គលិក ពេទ្យយ៉ាងតិច ២ ដង ក្នុង១ថ្ងៃ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុង គ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែង តែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

តារាងទី២. ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"**

| ពិន្ទុ | អត្រានៃការបង់ថ្លៃសេវា |
|---|---|
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬ តិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

ការទូទាត់ និងការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី៖

- **ភាគី "ក"** នឹងទូទាត់ ១០០% ទៅតាមប្រភេទករណី ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀង រហូតដល់មានការវាយតម្លៃសូចនាករណ៍គុណភាពសេវា។

- ការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី ត្រូវអនុលោមទៅតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាដូចមានចែងក្នុងតារាងទី២ ដែលធ្វើឡើងដោយ ប.ស.ស។

៣.៥ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ក"** ត្រូវផ្តល់នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ដល់ **ភាគី "ខ"** ។

៣.៦ ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានត្រលប់ទៅឲ្យ **ភាគី "ខ"** ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី "ខ"** ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

## ប្រការ ៤_. យន្តការដោះស្រាយវិវាទ

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

## ប្រការ ៥_. ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវា និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ)ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៦_. ប្រសិទ្ធភាព នៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី...........ខែ..............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**